BBI0088

**សម្ភាសន៍ជាមួយឈ្មោះធុយ ពៅ ភេទស្រី អាយុ៥៥ឆ្នាំ**

**សព្វថ្ងៃរស់នៅភូមិអូររំដួល ឃុំអូររំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង**

**មុខងារសម័យខ្មែរក្រហមៈ កសិករ**

**មុខងារបច្ចុប្បន្នៈ កសិករ**

**សម្ភាសន៍ដោយៈ ស សេងគា**

**សម្ភាសន៍ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១១**

**សរុបទំព័រៈ ២៣**

**០០:៥៨:១២**

សេងគាៈ ខ្ញុំសូមជម្រាបសួរអ៊ំ ខ្ញុំឈ្មោះ សេងគា ហើយខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ជាអង្គការទេ មិនមែនរដ្ឋាភិបាលទេ ហើយខ្ញុំក៏ជាអ្នកស្រុកបាត់ដំបងដែរ ខ្ញុំនៅស្រុកឯកភ្នំ

ពៅៈ ជិតៗគ្នាដែរ ខេត្តតែមួយ ។

សេងគាៈ អញ្ចឹងអ៊ំមកនៅនេះតាំងពីឆ្នាំប៉ុន្មានដែរអ៊ំ?

ពៅៈ ខ្ញុំមកនៅឆ្នាំផ្ដាច់ខ្លួនហើយ ។

សេងគាៈ អញ្ចឹងឆ្នាំ៩០ជាងហើយ?

ពៅៈ ចាំ! ប្រហែលជាឆ្នាំ៩២ ។

សេងគាៈ មិនមែនជាអ្នកនៅតាំង៧៩ផង?

ពៅៈ កាលពីដើមខ្ញុំនៅហ្នឹងដែរ តែកាលហ្នឹងគេដឹកជនភាសខ្លួនទៅខ្ញុំក៏ទៅ ដល់ពេលទៅនោះហើយ ទៅក៏មកកន្លែងដដែលវិញ ។

សេងគាៈ មកកន្លែងធ្លាប់រស់នៅ ។

ពៅៈ ចាំ!

សេងគាៈ ខ្ញុំមកថ្ងៃនេះគោលបំណងដែលខ្ញុំមកជួបអ៊ំនេះ ព្រោះចង់សម្ភាសន៍ពីជីវប្រវត្តិរបស់អ៊ំផ្ទាល់រឿងរ៉ាវដែលអ៊ំបានឆ្លងកាត់តាំងពីក្មេងមករហូតមកដល់ចាស់ រហូតដល់ពេលហ្នឹងអ៊ំមានជួបហេតុការណ៍អីខ្លះ ហើយអ៊ំមានជួបការលំបាកអីខ្លះកាលសម័យសង្គ្រាមហ្នឹង?

ពៅៈ សម័យសង្គ្រាមកាលពីជំនាន់មកមកជួបខ្មាំងមែនទែន ជួបខ្មាំងរហូតដល់ថ្នាក់ស៊ីបាយលូន ដូចថាកាលជំនាន់ហ្នឹងវាចេះតែរត់លូននោះ ។

សេងគាៈ ដូច្នេះហើយបានជាខ្ញុំចង់ដឹងចង់ឮពីរឿងហ្នឹង ។

ពៅៈ កាលពីសម័យហ្នឹងនាំគ្នារត់ឆ្លងពីកន្លែងមួយទៅកន្លែងមួយទៀត ហើយរត់ឡើងដាច់បាយដាច់ទឹកណា៎ពូ ដល់ពេលក្រោយមកគេបើកជំរុំហ្នឹងបាននាំគ្នារត់ចូលជំរុំទៅ ហើយបានអង្គការមនុស្សធម៌គេជួយទៅវាបានធូរមួយកម្រិតទៅ ហើយក្រោយមកបានគេដឹកជនភាសខ្លួនទៅបាន២-៣ឆ្នាំបានគេដកមកនេះវិញហ្នឹង គេដឹកទៅពី៨០ប៉ុន្មានទេកាលហ្នឹង គេដឹកជនភាសខ្លួនទៅហើយខ្ញុំក៏ភ្លេចទៅ ហើយក៏បានបកមកនៅនេះវិញបាន១០ឆ្នាំហើយ កាលពីដើមមកនៅបានដីគេ២០រ៉ៃ ហើយធ្វើចំការបាន៣-៤ឆ្នាំកូនវាចេះតែឈឺ ដំបូងវាចាញ់ណា៎ ហើយលក់ដីលក់ធ្លីមើលកូនអស់ សព្វថ្ងៃនៅសល់តែដីភូមិ ហើយកូនគេទៅនៅស្រុកថៃអស់ទៅ គេទៅរកស៊ីឈ្នួលគេទៅហើយខ្ញុំនៅមើលចៅចេះតែនៅធម្មតាទៅ ហើយទៅស៊ីឈ្នួលគេខ្លះអញ្ចឹងទៅ ហើយរកស៊ីសព្វថ្ងៃនេះចិញ្ចឹមតែខ្លួនឲ្យតែរស់ហ្នឹងព្រោះយើងវាអត់ដែរណា៎ វាឆ្លងកាត់ការលំបាកមកច្រើន កាលខ្ញុំរាប់ជំនាន់នោះ ដាច់បាយកូន ស៊ីដំឡូងស៊ីអីទៅ ហើយជួនកាលមានអង្ករមួយកំប៉ុងហ្នឹងបបរឲ្យកូនទៅ ហើយម៉ែឪហ្នឹងអត់អញ្ចឹងទៅ អាហ្នឹងកាលជំនាន់រត់ហ្នឹង ម៉ែឪហ្នឹងនាំគ្នាអត់បានតែកូនហូបហ្នឹង ជិតមួយឆ្នាំដែរហ្នឹងទម្រាំតែបានពួកជំរុំមកបានរត់ចូលជំរុំហ្នឹងណា៎ គ្រាន់តែរត់ឆ្លងកាត់ប៉ុន្មានឆ្នាំហ្នឹង ហើយដល់ក្រោយមកក៏បាននៅជាមួយខ្មែរក្រហមមិនទាន់ចូលជំរុំណា៎ ហើយពេលនៅហ្នឹងពេលគ្រាប់ផ្លោងមកក៏នាំគ្នារត់ នាំគ្នារត់ជ្រកតាមភ្នំតាមអីហ្នឹង ហើយនៅគីឡូ៩ ចក្រីអីគ្នាទូលទម្រាំតែមកដល់ អញ្ចឹងបានថាបានចូលជំរុំនេះបានធូរ ។

សេងគាៈ អញ្ចឹងខ្ញុំសូមសួរឈ្មោះអ៊ំ តើអ៊ំឈ្មោះអីដែរអ៊ំ?

ពៅៈ ខ្ញុំឈ្មោះ ធុយ ពៅ ។

សេងគាៈ អ៊ំអាយុប៉ុន្មានហើយ?

ពៅៈ ឆ្នាំថ្មីនេះ៥៥ហើយ ។

សេងគាៈ ស្រុកកំណើតរបស់អ៊ំនៅណាដែរ?

ពៅៈ ពីដើមខ្ញុំនៅថ្មគោល ដល់ហើយទៅខ្ញុំមកនៅភូមិថ្មីយើងនៅជ័យត្រែងណា៎ ។

សេងគាៈ អញ្ចឹងពីដើមអ៊ំនៅភូមិណា៎?

ពៅៈ ពីដើមខ្ញុំនៅភូមិអន្ត ។

សេងគាៈ ឃុំអី?

ពៅៈ ឃុំតាម៉ឺន ។

សេងគាៈ ឃុំតាម៉ឺន ស្រុកថ្មគោល?

ពៅៈ ចាំ! កាលពីដើមស្រុកបាត់ដំបង ខេត្តបាត់ដំបង ប៉ុន្តែក្រោយមកខ្ញុំមកនៅភូមិថ្មី

សេងគាៈ ហើយបច្ចុប្បន្ននៅនេះគេហៅភូមិរំដួល?

ពៅៈ ចាំ!

សេងគាៈ ឃុំរំដួលដែរ?

ពៅៈ ចាំ!

សេងគាៈ ហើយស្រុកភ្នំព្រឹក ខេត្តបាត់ដំបង?

ពៅៈ ចាំ!

សេងគាៈ ហើយឪពុកអ៊ំឈ្មោះអីដែរ?

ពៅៈ ឈ្មោះ សក់ ឆែម តែគាត់ស្លាប់ហើយ ។

សេងគាៈ ចុះម្តាយ?

ពៅៈ ម្តាយឈ្មោះ ធុយ សៀ ។

សេងគាៈ គាត់នៅរស់ទេអ៊ំ?

ពៅៈ គាត់ស្លាប់ហើយ ។

សេងគាៈ អញ្ចឹងអ៊ំយកត្រកូលតាមម្តាយ?

ពៅៈ ចាំ! ខ្ញុំយកត្រកូលតាមម្តាយ ធ្វើប្រវត្តិរូបមកប្តីខ្ញុំគាត់អត់ដឹង ដល់ពេលធ្វើកបីគាត់ដាក់ខាងម្តាយហើយគេយកតាមហ្នឹងហ្នងទៅ ។

សេងគាៈ អ៊ំមានបងប្អូនប៉ុន្មាននាក់?

ពៅៈ ខ្ញុំមានបងប្អូន៥នាក់ តែស្លាប់មួយសល់៤នាក់ ។

សេងគាៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាននាក់?

ពៅៈ ស្រី២នាក់ ហើយប្រុស៣នាក់ ស្លាប់នៅខ្មែរក្រហមគេយកទៅវៃចោល ។

សេងគាៈ ស្លាប់ហ្នឹងឈ្មោះអីគេ?

ពៅៈ ឈ្មោះ ឈន ស្លាប់ហ្នឹងគេចាប់ជិតផ្តាច់ខ្លួនហើយ គេយកមកវៃចោល ។

សេងគាៈ អញ្ចឹងអ៊ំអាចរៀបរាប់ឈ្មោះមួយៗបានទេ ដូចថាបងទី១ឈ្មោះអី?

ពៅៈ បងទី១ឈ្មោះ សក់ ឆោម ។

សេងគាៈ ប្រុសឬក៏ស្រីអ៊ី?

ពៅៈ ប្រុស ហើយបងទី២ស្រី ។

សេងគាៈ សក់ អី?

ពៅៈ សក់ ឈឿន ។

សេងគាៈ ហើយចុះទី៣?

ពៅៈ ទី៣ហ្នឹងខ្ញុំនេះឯង ។

សេងគាៈ ហើយចុះទី៤?

ពៅៈ ទី៤ឈ្មោះ សក់ ប៊ុន ។

សេងគាៈ ប្រុសឬស្រី?

ពៅៈ ប្រុស ។

សេងគាៈ ហើយទី៥ឈ្មោះ សក់ ឈន ហ្នឹង?

ពៅៈ ចា៎!

សេងគាៈ អញ្ចឹងស្លាប់កូនពៅ?

ពៅៈ ចា៎!

សេងគាៈ ឈន ហ្នឹងប្រុស?

ពៅៈ ប្រុស ។

សេងគាៈ អ៊ីមានកូនប៉ុន្មាននាក់អ៊ី?

ពៅៈ ខ្ញុំមានកូន៧នាក់ ។

សេងគាៈ ហើយមានប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ពៅៈ ស្រី៤នាក់ ហើយប្រុស៣នាក់ ។

សេងគាៈ នៅរស់ទាំងអស់ទេ?

ពៅៈ នៅទាំងអស់ ។

សេងគាៈ ហើយមានកើតទាន់ខ្មែរក្រហមខ្លះទេ?

ពៅៈ កើតទាន់មីបងគេ ។

សេងគាៈ បងហ្នឹងអាយុប៉ុន្មាន?

ពោះៈ បងអាយុ៣៣ហើយ ឆ្នាំម្សាញ់ប្រហែលជា៣៣ហើយ ហើយមួយទៀតឆ្នាំមមែអាយុ ៣០ ។

សេងគាៈ អញ្ចឹងខ្ញុំចង់សួរអ៊ីអំពីប្រវត្តិកាលពីនៅតូច កាលពីតូចអ៊ីចូលរៀននៅអាយុប៉ុន្មាន?

ពោះៈ ខ្ញុំរៀន តែរៀនអត់ចេះ កាលចូលរៀនហ្នឹងអាយុ៨-៩ឆ្នាំហ្នឹង កាលហ្នឹងរៀនគ្រូលោក ។

សេងគាៈ រៀននៅណាអ៊ី?

ពោះៈ ខ្ញុំរៀននៅសាលាវត្តភូមិថ្មីនេះ ។

សេងគាៈ ភូមិថ្មីហ្នឹង ឃុំអីគេ ។

ពោះៈ ឃុំឬស្សីត្រែង ហើយកាលពីដើមឃុំគោកឃ្មុំ ។

សេងគាៈ ស្រុកបាត់ដំបងដែរកាលហ្នឹង?

ពោះៈ ស្រុកបាត់ដំបង ។

សេងគាៈ ហើយអ៊ីរៀនបានថ្នាក់ទីប៉ុន្មានបានឈប់?

ពោះៈ កាលហ្នឹងមិនដឹងថ្នាក់ទីប៉ុន្មានទេ ព្រោះកាលហ្នឹងរៀនជាមួយលោក ។

សេងគាៈ ហើយរៀនបានប៉ុន្មានឆ្នាំ?

ពោះៈ រៀនបាន២-៣ឆ្នាំ តែគ្មានចេះអីទេ ។

សេងគាៈ អញ្ចឹងរៀនបាន៣ឆ្នាំ?

ពោះៈ ចាំ!

សេងគាៈ ហើយម៉េចបានឈប់?

ពោះៈ កាលហ្នឹងឈប់ដោយសារអញ្ចេះ ម៉ែអីនៅស្រែហើយយើងចេះតែទៅមកចោលគាត់អញ្ចឹងណាំ ដល់ពេលអញ្ចឹងទៅតាមគាត់ទៅ ហើយក៏អត់បានរៀនទៅ ។

សេងគាៈ ហើយដល់ពេលឈប់រៀនធ្វើអីទៀត?

ពោះៈ ឈប់រៀនជួយធ្វើការងារម៉ែដូចជា ដកស្ទូង ធ្វើស្រែ ។

សេងគាៈ រហូតដល់ឆ្នាំ៧០?

ពោះៈ ចាំ!

សេងគាៈ ចុះដល់ពេលឆ្នាំ៧០មិនធ្លាក់គ្រាប់បែករបស់ លន់ នល់ ហ្នឹង?

ពោះៈ ជំនាន់ហ្នឹងខ្មែរក្រហមកៀរចូលខ្មែរក្រហម ។

សេងគាៈ ទៅកៀរដល់ភូមិហ្នឹង?

ពោះៈ ហ្នឹងអើយ គេកៀយើងទៅ ។

សេងគាៈ គេកៀទៅទាំងអស់ហ្នឹង?

ពោះៈ ហ្នឹងអើយ ។

សេងគាៈ នៅភូមិថ្មីហ្នឹងមែន?

ពោះៈ ចា៎! គេកៀចូលទៅខ្មែរក្រហមហើយចូលទៅកំពីងពួយអីហ្នឹង ។

សេងគាៈ ហើយកាលហ្នឹងខ្មែរក្រហមណាអ្នកកៀ?

ពោះៈ ខ្មែរក្រហមមេគេឈ្មោះតា ភោគ សារី ។

សេងគាៈ កៀតាំង៧០ទៅ?

ពោះៈ កាលខ្មែរក្រហមកៀហ្នឹងឆ្នាំ៧៣ហើយ ។

សេងគាៈ អញ្ចឹងកាលពេល៧០នៅក្នុងភូមិនៅឡើយទេ?

ពោះៈ ចា៎! នៅក្នុងភូមិ ។

សេងគាៈ គាត់ធ្វើអីគេមេខ្មែរក្រហមហ្នឹង?

ពោះៈ គាត់ហ្នឹងរបៀបដូចថាចៅហ្វាយខេត្តអញ្ចឹងណា៎ អាហ្នឹងមេទ័ពចុះពី ប៉ុល ពត មក ហើយ ភោគ សារី ហ្នឹងដូចថាមេក្នុងមួយស្រុកអញ្ចឹងណា៎ គាត់ខាងគ្រប់គ្រងហើយដឹកនាំធ្វើខ្មែរក្រហមអញ្ចឹងណា៎ ។

សេងគាៈ ហើយមានស្គាល់អ្នកណាទៀតទេក្រៅពីមេ ភោគ សារី ហ្នឹង?

ពោះៈ ឈ្មោះតាអីទេ គាត់ហ្នឹងចៅហ្វាយស្រុក មិនមែន តាយ៉ៃ ទេលើ តាយ៉ៃ ហ្នឹងទៀតដែលនៅជិតយើងនៅថ្មគោលនោះ ឈ្មោះ តាតុំ តាតុំ ហ្នឹងគាត់មេហើយបន្ទាប់មក តាយ៉ៃ អាហ្នឹងមេជាន់ក្រោមទេណា៎ តាយ៉ៃ ហ្នឹងគាត់មេស្រុក ។

សេងគាៈ អញ្ចឹងតា ភោគ សារី គាត់ធំជាងគេ?

ពោះៈ ចា៎! មួយប៉ែកខាងហ្នឹងគឺតា ភោគ សារី ។

សេងគាៈ ហើយកាលហ្នឹងគេកៀប្រជាជនទាំងអស់?

ពោះៈ ចា៎! កៀហ្នឹងអ្នកណាផុតក៏ផុតទៅ ហើយខ្លះដោយមួយកំណាត់ទៅណា៎ ។

សេងគាៈ ហើយកាលពេលដែលកៀហ្នឹងគេកៀដាក់ឡានឬក៏ម៉េច?

ពោះៈ រទេះខ្លួនយើង រទេះគោ ក្របីហ្នឹងចេះតែបរទៅតាមគេអញ្ចឹងណា៎ ។

សេងគាៈ ហើយថាគេកៀចូលព្រៃហ្នឹង គេកៀចូលព្រៃណាទៅ?

ពោះៈ ព្រៃកំពីងពួយនេះ ។

សេងគាៈ អ៊ំ! មកខាងកំពីងពួយវិញ?

ពៅៈ ហ្នឹងអើយ មកខាងកំពីងពួយ ខាងព្រៃធំអីហ្នឹង តែកាលជំនាន់ហ្នឹងដូចឆ្ងាយអើយឆ្ងាយ កំពីងពួយអីហ្នឹង ។

សេងគាៈ ហើយពេលដែលគេកៀរមកហ្នឹង ពេលមកដល់ដំបូងគេឲ្យធ្វើអីខ្លះ ហើយមកតាមផ្លូវហ្នឹង មានជួបការលំបាកទេ?

ពៅៈ អត់មានគេធ្វើបាបធ្វើអីយើងទេ គេគ្រាន់តែកៀរយកកម្លាំងយើងមកបម្រើទ័ពនៅសម័យហ្នឹង ។

សេងគាៈ អញ្ចឹងមូលហេតុដែលគេកៀរព្រោះគេចង់យកកម្លាំងមកបម្រើទ័ព?

ពៅៈ ហ្នឹងអើយ ហើយដល់ពេលគេកៀរកូនយើងហ្នឹងស័គ្រធ្វើទ័ពធ្វើអីទៅ ហើយប្ដីខ្ញុំនេះសុទ្ធតែជាទ័ពហើយ ។

សេងគាៈ អញ្ចឹងគាត់ស័គ្រចិត្តធ្វើទ័ព?

ពៅៈ ចា៎! ចុះបើយើងមិនធ្វើម៉េចក្នុងរបបហ្នឹង បានធ្វើទ័ពក្នុងជំនាន់ហ្នឹងទៅ

សេងគាៈ អញ្ចឹងមុនពេលធ្វើទ័ពមុនដំបូងនៅកំពីងពួយ?

ពៅៈ ចា៎!

សេងគាៈ ហើយការហូបចុកអីយ៉ាងម៉េចដែរ អត់អីទេ?

ពៅៈ អត់ខ្លះ មានខ្លះអញ្ចឹងទៅ ។

សេងគាៈ ហើយគេកៀរពីភូមិរបស់អ៊ំទៅកំពីងពួយប៉ុន្មានថ្ងៃទៅដល់ទៅ?

ពៅៈ ១យប់១ថ្ងៃ ។

សេងគាៈ អញ្ចឹងពេលទៅដល់ហ្នឹងគេប្រកូកប្រកាសហ្មង គេប្រកូកប្រកាសថាឲ្យអ្នកណាធ្វើទ័ព ឬមួយក៏គេបង្ខំ?

ពៅៈ កាលហ្នឹងគេអត់ទាន់បង្ខំយើងទេណា៎ យើងនៅតាមសម្រួលថាអ្នកណាមានចិត្តស័គ្របាន គេជ្រើសរើសយើង ប្រុសៗធ្វើទ័ពអញ្ចឹងទៅ ហើយមានកូនស្រីអញ្ចឹងចូលនារីទៅ ។

សេងគាៈ ហើយចុះចាស់ៗ?

ពៅៈ ចាស់ៗនៅធ្វើស្រែធម្មតា ។

សេងគាៈ អញ្ចឹងគេយកតែកងយុទ្ធជនទេ?

ពៅៈ ហ្នឹងអើយ ។

សេងគាៈ ចុះមីងកាលហ្នឹងគេឲ្យមីងធ្វើអី?

ពៅៈ ខ្ញុំកាលហ្នឹងខ្ញុំនៅនារីហ្នឹងគេដែរ ។

សេងគាៈ កាលហ្នឹងអត់ទាន់មានគ្រួសារទេ?

ពៅៈ នូវ ។

សេងគាៈ ហើយកាលផ្ដើកងនារីហ្នឹងអត់ទាន់ស្គាល់ប្ដីទេ?

ពៅៈ អត់ទាន់ស្គាល់ទេ ។

សេងគាៈ នៅកន្លែងហ្នឹងកងពលគេហៅកងពលលេខប៉ុន្មាន?

ពៅៈ មានត្រឹមវរៈសេនាធំ ។

សេងគាៈ វរៈសេនាធំលេខប៉ុន្មាន?

ពៅៈ មិនដឹងដែរ ។

សេងគាៈ វរៈសេនាធំហ្នឹងដឹកនាំដោយលោក ភោគ សារី ហ្នឹងមែន?

ពៅៈ ហ្នឹងអើយ ។

សេងគាៈ ហើយក្រោមលោក រស់ ញឹម ហ្នឹងមានអ្នកណាគេទៀត?

ពៅៈ មានមេកងមានអីហ្នឹង ។

សេងគាៈ ដល់ពេលអញ្ចឹងពេលនៅកំពីងពួយហ្នឹងចូលហ្នឹង ពេលចូលបម្រើហ្នឹងហាត់ប៉ុន្មានខែ?

ពៅៈ ពេលគេហាត់គេហៅទៅហាត់ប៉ុន្មាន ដូចជាកន្លះខែអញ្ចឹងទៅ ។

សេងគាៈ ដល់ពេលហាត់ហើយទៅកាន់កាំភ្លើងអញ្ចឹងទៅ?

ពៅៈ ចាំ!

សេងគាៈ ហើយកាលហ្នឹងប្រយុទ្ធគ្នាជាមួយអ្នកណាគេ ជាមួយ លន់ នល់ មែន?

ពៅៈ ជាមួយ លន់ នល់ ។

សេងគាៈ ប៉ុន្តែកន្លែងនៅតែកំពីងពួយហ្នឹងទេ?

ពៅៈ ចាំ! នៅកំពីងពួយ ។

សេងគាៈ នៅបានប៉ុន្មានឆ្នាំ ប៉ុន្មានខែដែរ?

ពៅៈ នៅបាន១ឆ្នាំ ដូចជាមិនមែន១ឆ្នាំទេ តាំងពីឆ្នាំ៧៣ដល់ឆ្នាំ៧៥ ។

សេងគាៈ អញ្ចឹងបាន២ឆ្នាំ ។

ពៅៈ តាខ្ញុំគាត់នៅម្ដុំជិតឯកភ្នំដែរហ្នឹង ស្រុកកំណើតគាត់ ។

សេងគាៈ ដល់ហើយទៅណាទៀតទៅ ។

ពៅៈ ដល់ហើយចប់ហើយគេចូលទៅក្នុងវិញហើយ ។

សេងគា:	ចូលមកក្នុងវិញចូលមកណា?
ពៅ:	មកនៅថ្មគោលហ្នឹង ហើយខ្ញុំនៅនិមិត្ត ។
សេងគា:	ដល់ពេលវៃបែកភ្នំពេញក៏មកនៅនិមិត្ត?
ពៅ:	ចាំ!
សេងគា:	អ៊ំមានដែលមកដល់ភ្នំពេញទេ?
ពៅ:	អត់ដែលផង ។
សេងគា:	ដល់ពេលវៃបែកអស់ហើយក៏មកកន្លែងដើមវិញ?
ពៅ:	ហ្នឹងអើយ ។
សេងគា:	គេបំបែកឲ្យមក ឬក៏កងទ័ពគេជម្លៀស?
ពៅ:	កាលដំបូងខ្ញុំនៅទ័ព ដល់ហើយគេឲ្យខ្ញុំមករៀបគ្រួសារជាមួយគាហ្នឹងក៏បានមកនៅថ្មគោលហ្នឹង ។
សេងគា:	អញ្ចឹង៧៩មានគ្រួសារ?
ពៅ:	៧៦បានមាន ។
សេងគា:	អញ្ចឹងនៅថ្មគោលបាន១ឆ្នាំ ហើយ៧៦បានរៀបការ?
ពៅ:	ចាំ!
សេងគា:	ហើយពេលមកនៅថ្មគោលគេឲ្យធ្វើអីគេ ជាសហករណ៍ធម្មតាទេ?
ពៅ:	កាលហ្នឹងនៅក្តាប់កន្លែងកសិកម្មនៅថ្មគោល កន្លែងជាងឡាន ។
សេងគា:	ហើយចុះអ៊ំកាលហ្នឹងធ្វើអី?
ពៅ:	ខ្ញុំកាលហ្នឹងនៅធ្វើពេទ្យ ។
សេងគា:	អ៊ំ! អ៊ំគេឲ្យធ្វើខាងពេទ្យវិញ?
ពៅ:	ចាំ! កាលហ្នឹងធ្វើខាងជំនួយពេទ្យ ។
សេងគា:	ហើយធ្វើពេទ្យហ្នឹង ពេទ្យខាងស្រុកឬក៏ខាងអីគេ?
ពៅ:	ពេទ្យខាងកសិកម្មគេហ្នឹង ។
សេងគា:	មកដល់វិញហើយបានធ្វើពេទ្យមែនទេ?
ពៅ:	ចាំ!
សេងគា:	អញ្ចឹងឆ្នាំ៧៩អ៊ំពេទ្យ?

ពោះ	ចាំ! ដែលគេហៅពេទ្យឆ្មបហ្នឹង តែខ្ញុំមិនសូវហ៊ានបង្កើតព្រោះខ្លាច ហើយខ្ពើមទៀតផង ។

សេងគា:	នៅមន្ទីរកសិកម្ម?

ពោះ	ចាំ! កន្លែងជាងឡាន ជាងអាគ្រាក់ ។

សេងគា:	ដល់ពេលនៅហ្នឹងបាន១ឆ្នាំ ឆ្នាំ៧៦បានរៀបការ?

ពោះ	ចាំ!

សេងគា:	ហើយរៀបការហ្នឹងយើងស្រលាញ់គ្នា ឬក៏គេផ្គូរផ្គងឲ្យកាលហ្នឹង?

ពោះ	គេផ្គូរផ្គងឲ្យ ។

សេងគា:	អត់មានបានស្គាល់គ្នាទេ?

ពោះ	ចាំ!

សេងគា:	ហើយពីណាគេជាអ្នកផ្គូរផ្គងឲ្យពេលដែលអ៊ំមកនៅហ្នឹង?

ពោះ	មេយើង មេដែលកាន់កាប់យើងហ្នឹង ។

សេងគា:	មេរបស់អ៊ំឈ្មោះអី?

ពោះ	មេខាងខ្ញុំឈ្មោះ ឃឿន មេវរៈទាហាន ។

សេងគា:	គាត់មេវរៈ?

ពោះ	គាត់មេវរៈក្តាប់វរៈកងពល ដូចថាមួយកងវរៈអញ្ចឹងណាំ គេហៅមួយវរៈគេហ្នឹង ប្រហែលជាមួយកងពលហ្នឹង ។

សេងគា:	ហើយគាត់បានផ្សំផ្គុំអ៊ំឲ្យរៀបការជាមួយពូ?

ពោះ	ចាំ!

សេងគា:	ហើយពូឈ្មោះអីទៅ?

ពោះ	ឈ្មោះ អែម ឡាយ ។

សេងគា:	ហើយពេលផ្សំផ្គុំរៀបការហ្នឹង រៀបការប៉ុន្មានគូកាលហ្នឹង?

ពោះ	កាលហ្នឹងមាន៦គូរ ។

សេងគា:	អ៊ំមាននៅចាំគូរដែលរៀបការជាមួយអ៊ំទេ ពួកគេបាត់ទៅណាអស់ហើយ?

ពោះ	បែកគ្នាអស់ហើយ ។

សេងគា:	ហើយមុនពេលដែលគេឲ្យអ៊ំរៀបការគេមានប្រាប់អ៊ំថាម៉េចទេ?

ពៅៈ គេប្រាប់យើងដែរ គេប្រាប់ថាឥលូវដល់ពេលគេឲ្យយើងរៀបការហើយ ព្រោះយើងអាយុច្រើនហើយ ។

សេងគាៈ ហើយអ៊ំអត់មានប្រកែកទេកាលហ្នឹង?

ពៅៈ អត់មានប្រកែកផង ព្រោះយើងប្រកែកមិនបានសម័យហ្នឹង បើថាអ្នកកំប៉េចកំប៉ុកអីប្រកែកបាន តែដូចយើងមេកងមេក្រុមអញ្ចឹងគេចាប់គូរឲ្យយើងរៀបតែម្តង ។

សេងគាៈ កាលហ្នឹងអ៊ំធ្វើមេកង?

ពៅៈ ចា៎! មេកងតូច ។

សេងគាៈ មេកងតូចខាងពេទ្យ?

ពៅៈ ដូចថានៅខាងក្នុងនេះហ្នឹងខាងទាហាន ខាងនារី ដល់ពេលបានគានេះបានគេបញ្ចូលយើងខាងពេទ្យ ។

សេងគាៈ អញ្ចឹងទាល់តែបានអ៊ំប្រុសហើយបានធ្វើពេទ្យ?

ពៅៈ ចា៎!

សេងគាៈ ហើយចុះអ៊ំចូលខាងកងនារីហ្នឹង អ៊ំធ្វើខាងកងនារី?

ពៅៈ ចា៎! ដល់ពេលខ្ញុំបានគានេះបានគេបញ្ចូលខ្ញុំខាងពេទ្យ ។

សេងគាៈ អញ្ចឹងគេបង្ខំ ហើយប្រកែកអត់បានទេ ហើយមានភ្លេងមានភ្លើងអីទេកាលហ្នឹង?

ពៅៈ អត់មានទេ តែយើងជួលអ្នកធ្វើការអញ្ចឹងទៅ គេមានហៅពួកកម្មភិបាលគេហ្នឹងមកធ្វើម្ហូបអីត្រឹមត្រូវ ។

សេងគាៈ អ៊ឺ! កាលហ្នឹងមានកម្មាភិបាលមកចូលរួម?

ពៅៈ ចា៎!

សេងគាៈ កម្មាភិបាលឈ្មោះអីគេ?

ពៅៈ កាលហ្នឹងមានឈ្មោះ តាយ៉ួម, តាគុំ ។

សេងគាៈ មាន តាយ៉ួម?

ពៅៈ ចា៎! ហើយមាន តាវ៉ាត ខាងសេដ្ឋកិច្ចភូមិភាគ ។

សេងគាៈ តាយ៉ួម ហ្នឹងធ្វើអី កម្មាភិបាល?

ពៅៈ ប្រធានកសិកម្ម ហើយ តាវ៉ាត នោះខាងសេដ្ឋកិច្ចភូមិភាគ គេគិតគូរៀបចំឲ្យយើងថ្ងៃហ្នឹងអ្នកណាជួបក៏ជួប ហើយអ្នកណាបែកក៏បែកទៅ ។

សេងគាៈ ហើយចុះ តាគុំ គាត់គណៈតំបន់?

ពៅ: ចា៎!

សេងគា: ហើយចុះ រស់ ញឹម គាត់អត់មានមកចូលរួមទេ?

ពៅ: អត់ទេ តា រស់ ញឹម សម័យហ្នឹងគាត់អត់ទាន់ងាប់ទេ គាត់នៅបាត់ដំបង មកតែគណៈភូមិភាគទេ ។

សេងគា: ហើយចុះតា ភោគ សារី នោះ?

ពៅ: ភោគ សារី ក៏អត់មកដែរ ។

សេងគា: ហើយប្រធានកងប្រធានអីហ្នឹងមកជុំគ្នាទាំងអស់គ្នា?

ពៅ: ចា៎!

សេងគា: ប្រធានកងមានអ្នកណាគេខ្លះកាលហ្នឹង?

ពៅ: ប្រធានកងខាងខ្ញុំមានតែបង យឿន ហ្នឹងវរៈសេនាធំ អាហ្នឹងគាត់មក ដូចថាកងៗដូចគ្នាហើយស្គាល់គ្នាគេចេះតែមកទៅ ។

សេងគា: ចុះ៩គូរទៀតអ្នកដែលរៀបការជាមួយហ្នឹងគាត់ធ្វើអីគេ?

ពៅ: ពួកគេហ្នឹងធ្វើជាងដែរហ្នឹង ធ្វើជាងខ្លះ បើកឡានខ្លះ ។

សេងគា: អញ្ចឹងអ្នកដែលមានឋានៈរាងធំហ្នឹងមានតែមីងមួយទេ?

ពៅ: ចា៎!

សេងគា: ពួកគាត់សុទ្ធតែពួកមេកងដែរមែន?

ពៅ: ចា៎! សម័យហ្នឹងដូចថាអ្នកដែលរាងនេះអញ្ចឹងគេយកមករៀបជាមួយគ្នាអញ្ចឹងណា៎ អ្នកណាមានឋានៈហ្នឹងរៀបជុំគ្នាអញ្ចឹងទៅ ។

សេងគា: អញ្ចឹងអ៊ំអាចរៀបរាប់ហូរហែរពីឆ្នាំ៧៥មកទេ អ៊ំចាំបានប៉ុន្មានយកប៉ុណ្ណឹងទៅ រៀបរាប់ដូចថាបន្ទាប់ពីរៀបការហើយវាយ៉ាងម៉េចអីយ៉ាងម៉េច រហូតពីក្នុងរហូតដល់បែកណា៎?

ពៅ: កាលសម័យហ្នឹងពេលដែលខ្ញុំរៀបការហើយខ្ញុំមកនៅកន្លែងជាងកសិកម្មហ្នឹងណា៎ ហើយកន្លែងជាងហ្នឹងវាចេះតែផ្លាស់ប្តូរ ដូចថាបន្តិចដូរមេ ហើយបន្តិចចាប់មេយកទៅវ៉ៃចោល ចាប់មេខ្មែរក្រហមដូចគ្នា ចាប់មួយៗយកទៅវ៉ៃចោលទៅរហូតទៅដល់ឆ្នាំរដ្ឋហ្នឹង តាខ្ញុំគាត់ធ្វើល្អជាមួយប្រជាជន ដល់ពេលនារតីចូលមកគេស្រាវជ្រាវរកឈ្មោះតាខ្ញុំហ្នឹង ហើយតាខ្ញុំកូនសោរគាត់ច្រើន កូនសោរឃ្លាំងគ្រប់កន្លែង ហើយគាត់ក៏យកកូនសោរហ្នឹងមកបោះឲ្យខ្ញុំ ហើយប្រជាជនគេចេះតែជួយលាក់ ដល់ពេលគេរកចាប់គេ

សួរថាចុះអ្នកណាប្រពន្ធ ហើយខ្ញុំក៏ឆ្លើយថាខ្ញុំហ្នឹងប្រពន្ធ ហើយគេសួរថាគាត់ទៅណា ខ្ញុំក៏ឆ្លើយថាមិនដឹងគាត់ទៅណាទេ ព្រោះពេលដែលបែកមកគាត់បែកពីខ្ញុំ ខ្ញុំកុហកគេថាអញ្ចឹងណា៎ ដល់ពេលក្រោយមកគេសុំកូនសោរខ្ញុំ ហើយខ្ញុំក៏ឲ្យកូនសោរហ្នឹងទៅនារតីទាំងអស់ទៅណា៎ ហើយបានប្រជាជនគេជួយឆ្លើយថា កុំចាប់គាត់អី ព្រោះមនុស្សគាត់ល្អណាស់ មនុស្សគាត់ហ្នឹងប្រជាជនគេគាំទ្រគាត់ ហើយនារតីក្រោយមកក៏រហូតដល់យួនចូលមកយួនចាប់ប្តីខ្ញុំ គេចាប់ប្តីខ្ញុំព្រោះគេថាយើងធ្វើការធំណា៎ ហើយក៏ប្រជាជនផ្តិតមេដៃតវ៉ាថាគាត់ស្លូតត្រង់ណាស់ ធ្វើនាយកនៅក្នុងកន្លែងហ្នឹងគាត់មិនដែលធ្វើបាបសម្លាប់អ្នកណាទេ គេផ្តិតមេដៃហើយប្តីខ្ញុំជាប់៩ថ្ងៃក៏យួនគេលែងមកវិញ ហើយក្រោយក៏ចេះតែរត់ៗទៅ ហើយឡើងដល់ជំរុំហ្នឹង ចេះតែគេចរត់តាមនេះមកដាច់បាយដាច់ទឹក កាលហ្នឹងឆ្នាំ៨២-៨៣គេដឹកទៅវិញហ្នឹង ម៉ោង៣គេមកដឹក ។

សេងគា: អញ្ចឹងខ្ញុំសុំសួរបន្ថែមតិច ម៉េញឆ្នាំ៧៦អ៊ំរៀបការ ដល់ពេលរៀបការហើយអ៊ំនៅខាងសេដ្ឋកិច្ចខាងកសិកម្មហើយនឹងមន្ទីរ?

ពៅ: ចា៎!

សេងគា: ដល់ពេលរៀបការហើយគេឈប់ឲ្យធ្វើប្រធានកង ហើយមកនៅពេទ្យវិញ?

ពៅ: ចា៎! មកនៅខាងពេទ្យវិញ ។

សេងគា: ហើយនៅបានប៉ុន្មានឆ្នាំបាននារតីចូលមក?

ពៅ: ឆ្នាំ៧៦នារតីចូលហើយ ។

សេងគា: អញ្ចឹងចុង៦៧?

ពៅ: ហ្នឹងអើយ ចុង៧៦នារតីចូលមក អត់ទេដូចជា៧៧ ខែ៧ ។

សេងគា: ពួកនារតីហ្នឹងមានស្គាល់ឈ្មោះទេ?

ពៅ: នៅហ្នឹងមានឈ្មោះ រ៉ង អាហ្នឹងស្រី ហើយប្រុសឈ្មោះ អាយ៉ាន កាលហ្នឹងនារីហ្នឹង៦ង់គេមកកាន់កាប់កន្លែងយើង កន្លែងកសិកម្មហ្នឹង ។

សេងគា: ឈ្មោះ រ៉ង?

ពៅ: ចា៎! គេមកពីស្រែអំបិល ហើយ យ៉ាន ហ្នឹងរងទេ ។

សេងគា: បន្ទាប់ពីមកគ្រប់គ្រងហើយគេចង់ចាប់ពួយកទៅ?

ពៅ: ចា៎! ហើយតាខ្ញុំក៏គេចង់ចាប់ដែរ ។

សេងគា: ហើយម៉េចបានដឹងមុនថាគេចង់ចាប់?

ពៅៈ ចុះគេចាប់ តាតុំ គេចាប់ពីមុខអញ្ចឹងហើយ ។

សេងគាៈ អាហ្នឹងមកអត់ទាន់ដល់?

ពៅៈ ចាំ! មកអត់ទាន់ដល់ ។

សេងគាៈ អញ្ចឹងគេចាប់ តាតុំ ទៅអស់ហើយ?

ពៅៈ ចាំ! គេចាប់តាហ្នឹងហើយមាននារសាគាត់ស្គាល់ខ្ញុំក៏មកប្រាប់ ។

សេងគាៈ នារសាហ្នឹងឈ្មោះអីគេ?

ពៅៈ ឈ្មោះ អាវី ។ ហើយកាលហ្នឹងគេចាប់ហើយបានវារត់មកប្រាប់ថាគេចាប់តាហើយ ហើយតាខ្ញុំចេះតែគេច១ទៅ ដល់ក្រោយមកចូលវិញបាន ។

សេងគាៈ ហើយដល់ពេលរត់មកប្រាប់ហើយ ដល់ពេលពូឃើញក៏រត់ទៅ?

ពៅៈ ចាំ! គាត់ចេះតែគេចខ្លួនតាមប្រជាជនទៅ ហើយដល់ពេលរាងស្ងប់បន្តិចទៅយួនចូល ហើយគេជម្លៀសគាត់ផុតមក បើតាខ្ញុំចូលមកនៅកន្លែងវិញបាន កន្លែងនៅផ្ទះហ្នឹងអត់មានធ្វើអីទេ ព្រោះគេលែងឲ្យយើងធ្វើអីទៀតហើយ ។

សេងគាៈ ហើយកាលហ្នឹងឆ្នាំប៉ុន្មានហើយ?

ពៅៈ ឆ្នាំ៧០ ។

សេងគាៈ អញ្ចឹងប៉ុន្មានឆ្នាំជាប់គ្នា តាំងពីឆ្នាំ៧៧រហូតដល់៧៨ គ្រាន់តែរត់១ឆ្នាំជាងហើយ?

ពៅៈ ចាំ! គាត់រត់គេចរហូត ។

សេងគាៈ ប៉ុន្តែគេអត់ធ្វើបាបមីងទេ?

ពៅៈ គេអត់មានធ្វើបាបទេ ហើយប្រជាជនហ្នឹងគេចេះតែឆ្លើយឲ្យយើងទៅណាំ ចុះបើយើងមិនដឹង ហើយយើងមិនដែលធ្វើអីមែន ។

សេងគាៈ អញ្ចឹង១៩៧៩ហ្នឹងវៀតណាមចូលមក?

ពៅៈ ចាំ! វៀតណាមចូលមកហើយមានគេប្តឹងឲ្យវៀតណាមចាប់គាត់ វៀតណាមចាប់គាត់ ៥ថ្ងៃ តែបានប្រជាជនគេផ្តិតមេដៃឲ្យដោះលែងគាត់មកវិញ ។

សេងគាៈ ប្រជាជនមានធ្វើបាបដែរទេ?

ពៅៈ អត់មានធ្វើបាបទេ ហើយអត់ដែលមានជួបខសក្តិទេ ។

សេងគាៈ ហើយវៀតណាមមានដែលធ្វើបាបទេ?

ពៅៈ អត់ទេ ព្រោះពេលដែលចាប់ទៅដូចថាមានអ្នកចាស់ភូមិស្រុកហ្នឹងគេតាមប្តីខ្ញុំជាប់

សេងគាៈ នៅពេលដែលចាប់បាន៥ថ្ងៃ ហើយចុះពួកនារតីវៀតណាមចាប់បានប្តមួយក៏រត់?

ពោះ	រត់បាត់អស់ហើយ ពួកនារតីរត់មកនេះអស់ ហើយបានចាប់បានមួយសារបានពួកខ្ញុំមកពីក្រោយមួយសារទៀត វាកៀរពីបីជាន់ ។

សេងគា:	អញ្ចឹងដល់ឆ្នាំ៧៩ ហើយបានបកមកវិញ?

ពោះ	ចាំ!

សេងគា:	ហើយពេលដែលវៀតណាមលែងហើយគេឲ្យពូធ្វើអីទៀតកាលហ្នឹង?

ពោះ	អត់មានធ្វើអីទេ ។

សេងគា:	ដល់ពេលប្រជាជនផ្ដិតមេដៃហើយវៀតណាមក៏លែងវិញទៅ?

ពោះ	គេលែងមកវិញ ។

សេងគា:	ហើយអ៊ំអត់មានគេធ្វើបាបទេ?

ពោះ	អត់មានទេ ។

សេងគា:	កាលហ្នឹងមានជួបហេតុការណ៍ដូចគេសម្លាប់មនុស្ស ហើយពួកនារតីគេធ្វើបាបមានទេ?

ពោះ	វាពិបាកដូចថាមានហេតុការណ៍គេមិនដែលឲ្យយើងដឹងទេ?

សេងគា:	គេអត់ឲ្យយើងដឹងទេ?

ពោះ	ហ្នឹងអើយ ។

សេងគា:	ហើយអ៊ំអត់ដែលមានប្រទះឃើញទេ?

ពោះ	អ៊ំ! បើថាជួបអញ្ចឹងលែងហ៊ានទៅជិតហ្នង ព្រោះតែគេដឹងគេសម្លាប់ទាំងយើងណាំ ដូចថាគេចាប់មួយហើយគេចាប់មួយទៀតដូចខ្មែរអញ្ចឹងណាំ ហើយយើងគេចយកតែរួចខ្លួនទេ ។ ហើយដូចសម័យហ្នឹងគេបាញ់នៅថ្មគោល គេបាញ់ស្រស់ៗដែរហ្នឹង កាលឆ្នាំយួនចូលហ្នឹងដូចថា មនុស្សនៅតែខាងនោះបាញ់ទេ ហើយយើងខាងនេះអត់ដឹងណាំ ចុះរត់បណ្ដើរអើបណ្ដើរ ។

សេងគា:	ចុះអ៊ំនៅពេទ្យមានដែលឃើញអ្នកជម្ងឺមកច្រើនទេ?

ពោះ	មកច្រើន ។

សេងគា:	ប្រធានពេទ្យឈ្មោះអីទៅ?

ពោះ	ប្រធានពេទ្យឈ្មោះអីទេ ខ្ញុំភ្លេចឈ្មោះវាហើយ ឈ្មោះ រី ។

សេងគា:	គាត់ហ្នឹងជាមនុស្សយ៉ាងម៉េចដែរ?

ពោះ	មនុស្សហ្នឹងមានអី មនុស្សគេល្អហ្នឹង ។

សេងគា:	ហើយអ្នកជម្ងឺព្យាបាលហ្នឹងមានថ្នាំព្យាបាលទេ?

ពៅៈ សម័យហ្នឹងថ្នាំមានមិនគ្រប់គ្រាន់ទេ ។

សេងគាៈ មានថ្នាំអីខ្លះទៅ?

ពៅៈ មានថ្នាំដបទឹកក្រូចហ្នឹង

សេងគាៈ ដបទឹកក្រូចហ្នឹងគេហៅថ្នាំអីគេ?

ពៅៈ ថ្នាំរបៀបដូចថាថ្នាំខ្មែរណា៎ ថ្នាំស្ងួរ ហើយថ្នាំគ្រុនក្ដៅអីហ្នឹង ។

សេងគាៈ ហើយមានពណ៌អីខ្លះ?

ពៅៈ មានពណ៌ស មានពណ៌ទឹកក្រូច វាមកមួយឈុតៗគេហ្នឹង ។

សេងគាៈ ហើយថ្នាំហ្នឹងយកពីណាមក?

ពៅៈ មិនដឹងគេផលិតពីណាមក ។

សេងគាៈ ហើយកាលហ្នឹងអត់សូវមានអ្នករបួសច្រើនទេកាលហ្នឹង?

ពៅៈ មិនសូវមានអ្នករបួសដែរទេកាលជំនាន់ហ្នឹង កាលពីសម័យនារតីមកអត់ដែលមានគ្រោះថ្នាក់ទេ ។

សេងគាៈ អត់ដែលមានគ្រោះថ្នាក់ទេ សុខសាន្តរហូត ដល់ពេលយួនមកបានមានគ្រោះថ្នាក់?

ពៅៈ ចា៎! កាលហ្នឹងមកមួយឆាវ បើនិយាយរួមទៅកាលហ្នឹងខ្មែរក្រហមជាអ្នកបាញ់ សម័យហ្នឹងយួនមិនហ៊ានបាញ់ទេ ខ្មែរក្រហមកាលហ្នឹងគេរត់បណ្ដើរ បាញ់បណ្ដើរ ហើយគេជេញមកអញ្ចឹងអ្នកណាមិនមកគេបាញ់ចោល កាលហ្នឹងគេកៀរប្រជាជនមក ។

សេងគាៈ ហើយអាថ្នាំដូចដបទឹកក្រូចហ្នឹងថ្នាំអីគេ ថ្នាំអាចម៍ទន្សាយមែន?

ពៅៈ ហ្នឹងអើយថ្នាំអាចម៍ទន្សាយ ។

សេងគាៈ ហើយកាលហ្នឹងព្យាបាលហ្នឹងយ៉ាងម៉េចដែរ ព្យាបាលទៅជាទេ?

ពៅៈ ដូចថាថ្នាំអាចម៍ទន្សាយគេហ្នឹងលេបទៅវាធម្មតា វាមិនមានប្រសិទ្ធភាពអីផង ហើយកាលហ្នឹងវាមានថ្នាំល្អ កាលហ្នឹងវាមានខ្លះតែលុះត្រាតែអ្នកចាំបាច់បានគេប្រើ ។

សេងគាៈ អ្នកចាំបាច់យ៉ាងម៉េចទៅ?

ពៅៈ ដូចថាអ្នករបួសហ្នឹងធ្ងន់ធ្ងរបានគេយកថ្នាំហ្នឹងមកប្រើ ។

សេងគាៈ អ្នករបួសហ្នឹងអ្នកតូចឬក៏អ្នកធំ?

ពៅៈ អ្នកតូច ទ័ពយើងធម្មតាដែរតែឲ្យតែមានរបួសអីគេប្រើថ្នាំហ្នឹងណា៎ ។

សេងគាៈ របួសធំយ៉ាងម៉េចទៅ?

ពោះ: របៀបដូចថាត្រូវគ្រាប់ធូន់ធូរណ៎ា ហើយគេយកថ្នាំល្អហ្នឹងមកប្រើ ហើយទាល់តែអ្នកឈឺធ្ងន់បានគេយកមកប្រើណ៎ា ហើយដូចគ្រូនយើងធម្មតាយើងលេបថ្នាំអាចម៍ទន្សាយទៅ វាមានតិចតួចអាថ្នាំហ្នឹង ដូចថាសម្រាប់អ្នកដែលខ្លាំង ។

សេងគា: ហើយក្នុងពេទ្យហ្នឹងមានគ្នាប្រហែលជាប៉ុន្មាននាក់ទៅ?

ពោះ: ក្នុងពេទ្យហ្នឹងមានសង្គមកិច្ចហ្នឹង៥នាក់ ហើយក្នុងពេទ្យហ្នឹង១០នាក់ ។

សេងគា: មានចាំឈ្មោះអស់ទេ?

ពោះ: ចាំមិនអស់ទេ កាលហ្នឹងស្គាល់តែដូចថាយើងវាមិនចាប់អារម្មណ៍ ។

សេងគា: អញ្ចឹងស្គាល់តែមិត្តនារីមួយហ្នឹងទេ?

ពោះ: ចា៎! អាហ្នឹងមេគេណ៎ា ។

សេងគា: ហើយចុះមេបន្ទាប់?

ពោះ: ក្រោមហ្នឹងឈ្មោះ វ៉ាន អាហ្នឹងអនុប្រធាន មានតែ២នាក់ហ្នឹង ហើយកាលហ្នឹងតាសង្គមកិច្ចឈ្មោះ តាយឿម ប្រធានសង្គមកិច្ចនៅហ្នឹង អាហ្នឹងគាត់ថាថ្នាំខ្មែរ តែឥលូវស្លាប់អស់ហើយ ។

សេងគា: ហើយមីងក្រៅពីធ្វើពេទ្យហ្នឹង គេមានឲ្យធ្វើអីទៀតទេ?

ពោះ: អត់មានទេ ។

សេងគា: ធ្វើពេទ្យហ្នឹងរហូតដល់វៀតណាមចូលមក?

ពោះ: ខ្ញុំធ្វើពេទ្យត្រឹមនារតីចូលមកខ្ញុំឈប់ ។

សេងគា: ដល់ពេលនារតីគេសើររើរកចាប់ពូហ្នឹងបានមីងឈប់?

ពោះ: ចា៎! គេថាកាលហ្នឹងអ្នកណាធ្វើធំនៅខាងពាយ័ព្យ នារតីមកត្រូវតែចាប់ហើយ វាពីរដំណាក់អញ្ចឹងណ៎ា ដល់ពេលអញ្ចឹងទៅយើងអត់មានឲ្យគេដឹងថាខ្ញុំនេះធ្វើអីទេណ៎ា ដឹងតែប្ដីខ្ញុំទេ ។

សេងគា: អញ្ចឹងអត់មានប្រាប់គេថាអីធ្វើពេទ្យទេ?

ពោះ: អត់មានប្រាប់ទេ ។

សេងគា: អញ្ចឹងគេអត់ដឹងទេ ។

ពោះ: អត់ដឹងទេ ព្រោះប្រជាជនគេជួយលាក់យើងដែរហ្នឹង ។

សេងគា: អញ្ចឹងមីងក៏គេអត់ធ្វើបាបទៅ?

ពោះ: ចា៎! គេអត់ធ្វើបាបទេ ។

សេងគា: ហើយកាលហ្នឹងមានកូននូវ?

ពោះ: មានកូនមួយមីងបងគេ ហើយប្រសិនបើប្រជាជនគេស្អប់យើងគេចង្អុលយើងហើយ តែប្រជាជនគេជួយយើង កាលហ្នឹងចាប់អស់ច្រើនដែរ មើលកាលហ្នឹងអ្នកនៅជាមួយ អង្គភាពតាខ្ញុំគេចាប់ តាញ៉ែម នោះគេចាប់ ហើយដូចថា អាប៉ែន នោះវាឃោឃៅ ណាស់កាលសម័យនោះ ចិត្តវាឃោឃៅ ហើយវាចាប់ប្រជាជនវៃចង់ងាប់ ។

សេងគា: អាហ្នឹង៧៩ហើយមែនទេ?

ពោះ: ចា៎! ៧៩ហើយ ។

សេងគា: ៧៩ហើយគេវៃហ្នឹង?

ពោះ: គេវៃសឹងតែសម្លាប់ហ្នឹង ។

សេងគា: ប្រជាជនអ្នកចាប់វៃឈ្មោះ ប៉ែន ហ្នឹង?

ពោះ: ប្រជាជននៅហ្នឹង ហើយប្រជាជននៅខាងក្រៅ កុំតែបានគេមកជួយកុំអីគេវៃស្លាប់បាត់ហើយ ។

សេងគា: វៃនៅកន្លែងណា ហើយភូមិអី?

ពោះ: នៅប៉ោយយ៉ុង នៅជាប់កន្លែងកសិកម្មថ្មគោល កន្លែងទល់មុខសាលារៀនកិលេស ។

សេងគា: ហើយរាល់ថ្ងៃនៅជិតសាលាកិលេសហ្នឹង?

ពោះ: រាល់ថ្ងៃអត់នៅហ្នឹងទេ ឈឺងាប់ ។

សេងគា: អត់ទេ និយាយកន្លែងគេវៃ?

ពោះ: ចា៎! នៅខាងកើតសាលារៀនហ្នឹង កាលហ្នឹងប្រជាជនវៃផ្ទាល់ហ្នឹង អាហ្នឹងអង្គភាពជាមួយតាខ្ញុំ ។

សេងគា: ប៉ុន្តែពូថាបានអ្នកណាគេជួយវិញ?

ពោះ: បាន តាបាន គាត់ជួយ ហើយ តាបាន ហ្នឹងបើនិយាយទៅគាត់ជាមេខ្មែរក្រហមដែរ តែដល់សម័យហ្នឹងគាត់ចាស់ទៅគេលែងឲ្យគាត់ធ្វើអីហើយ បានតាហ្នឹងហើយគាត់ធានា ។

សេងគា: ដល់ពេលធានាទៅប្រជាជនឈប់វៃគាត់ទៅ ។

ពោះ: ហ្នឹងអើយ បានគាត់ទៅធានាថាវៃប៉ុណ្ណឹងបានហើយ ។

សេងគា: ហើយក៏រស់ដល់សព្វថ្ងៃទៅ?

ពោះ: ចា៎!

សេងគា: ហើយទើបតែស្លាប់ទេ?

ពៅ: ចា៎! គាត់ទើបតែស្លាប់ទេ ដោយសារជម្ងឺខ្លួនឯង ។

សេងគា: គាត់ឃោឃៅយ៉ាងម៉េចទៅ?

ពៅ: ដូចថាកាលហ្នឹងប្រជាជនមានអីស៊ីអញ្ចឹងដូចថាចេះតែរិះគន់គេ ដូចថាប៉ុនរាយការណ៍ តែប្ដីខ្ញុំអន្តភាពហ្នឹងគេដែរ គេធ្វើអីធ្វើទៅខ្ញុំអត់រវល់ ហើយបើមិនឲ្យគ្នាស៊ីបានអី ដូចថាប្រជាជនបានស៊ីអញ្ចឹងទៅវាចេះតែនិយាយ ដល់ពេលអញ្ចឹងទៅប្រជាជនគេស្អប់ណា៎ ដល់ពេលក្រោយមកគេបំបែកក្រុមជាង ហើយអ្នកណាស្ម័គ្រទៅបម្រើកម្មាភិបាលណាមួយអញ្ចឹងណា៎ គាត់ខ្ញុំរកកន្លែងដាក់អត់បាន ព្រោះប្រជាជនរត់មកនៅជាមួយ រកកន្លែងដាក់ប្រជាជនអត់បាន គេសុំមកនៅជាមួយ ចុះបើប្រជាជនគេថាបងអើយធ្វើអានេះម្ដង ហើយាគាត់ថាធ្វើទៅ ធ្វើនំបញ្ចុកធ្វើទៅ ហើយបើប្រជាជនកន្លែងខ្ញុំហ្នឹង២០០គ្រួសារគាត់ខ្ញុំដាក់ដល់៣០០ ដាក់ហ្នឹងដាក់យករបបមកឲ្យប្រជាជនស៊ី ដាក់ឈ្មោះពន្លើសយកអង្ករមកឲ្យប្រជាជនណា៎ ។

សេងគា: ហើយចុះកាលសម័យពី៧៥ដល់៧៩ហ្នឹងពូមិននៅខាងកសិកម្មមែនទេអី?

ពៅ: ចា៎!

សេងគា: ហើយការហូបចុកយ៉ាងម៉េចដែរ?

ពៅ: ហូបចុកកាលសម័យហ្នឹងក្នុងមួយនាក់គេឲ្យកន្ទះកំប៉ុង អាហ្នឹងការហូបចុក តែកន្លែងខ្ញុំអត់សូវខ្វះខាតទេ ព្រោះគាត់ខ្ញុំគាត់ទាក់ទងកន្លែងគេ ខាងទ្រព្យភា អាហ្នឹងពួកម៉ាកស្និទ្ធម្លោះហើយគាត់ចេះតែទាក់ទងទៅ ជួនកាលត្រីងៀតមួយឡានមកដាក់ឲ្យអញ្ចឹងទៅ ហើយគេផ្សេងៗគឺមិនបានទេ ជួនកាលពងទាមានមួយពាន់គ្រាប់គេដឹកយកមកឲ្យអញ្ចឹងទៅ អាហ្នឹងដោយសារគាត់ទាក់ទងគេដើម្បីឲ្យប្រជាជនណា៎ ហើយកន្លែងខ្វះរកតែអំបិលហូបមិនបានផង តែកន្លែងដូចថាវាមិនសូវលំបាកប៉ុន្មានទេ ហើយមិនដែលឲ្យប្រជាជនហូបបបរទេ កាលដែលខ្ញុំមកនៅក្នុងហ្នឹងណា៎ ។

សេងគា: អញ្ចឹងបានប្រជាជនគាត់ស្រលាញ់ ។

ពៅ: ចា៎! ចុះបើប្រជាជនតែ២០០នាក់ទេ តែគាត់ខ្ញុំគាត់ដាក់៣០០នាក់ ហើយគេមិនមែនមកពិនិត្យយើងណា៎ សម័យហ្នឹងមិនមែនដូចសម័យយើងនេះទេណា៎ ម្លោះហើយគេបើកតាមហ្នឹងមក ហើយខ្ញុំទៅប្រជុំហ្នឹងសុំឲ្យប្រជាជនបិទមាត់ទាំងអស់បើចង់ឆ្អែតគ្រប់គ្នាកុំឲ្យថាប្រជាជនមានកម្លាំងប៉ុណ្ណេះ ហើយគេមកសួរថាក្រុមកម្លាំងកសិកម្មមានកម្លាំង

|  |  |
|---|---|
|  | ប៉ុន្មាន ហើយឲ្យឆ្លើយតាមខ្ញុំ កម្លាំងមាន៣០០ឆ្លើយថា៣០០ ដល់ពេលអញ្ចឹងទៅវាមិនសូវជាខុះខាតប៉ុន្មានដែរ វាគ្រាន់មួយទប់ទល់ណា បើមិនបានរបស់មកពីហ្នឹងតារបស់ខ្ញុំមិនបានរស់នៅមកដល់ប៉ុណ្ណឹងទេ គេវៃចោលជិនាន់ហ្នឹងអើយ ។ |
| សេងគា: | ហើយពេលដែលចប់វៀតណាមហើយធ្វើអីទៀតទៅ វៀតណាមគេអត់មានឲ្យពូធ្វើមេភូមិអីទេ? |
| ពោ: | អត់មានទេ នៅជាប្រជាជនធម្មតាហ្នឹង ។ |
| សេងគា: | ហើយទាល់តែបែកវៀតណាមហើយបានប៉ុន្មានឆ្នាំបានរត់មកនេះវិញ? |
| ពោ: | បែកវៀតណាមមក មកនៅនោះបានមួយឆ្នាំ ។ |
| សេងគា: | អញ្ចឹង៨០? |
| ពោ: | ចាំ! ហើយចេះតែបណ្ដើរមកបានចូលជំរុំ ។ |
| សេងគា: | ចុះឆ្នាំ៨០ម៉េចបានជារត់មក? |
| ពោ: | ៨០រត់មកហ្នឹងដោយសាររកអីឲ្យកូនស៊ីមិនបានហ្នឹង ដូចថាវាពិបាកពេក ហើយក៏មកតាមខ្សែជំរុំហ្នឹងមក ។ |
| សេងគា: | រត់ចេញពីណាមក? |
| ពោ: | ពីថ្មគោលមកផ្លូវយើងខ្វាំងរាប់ហ្នឹង ។ |
| សេងគា: | ហើយចេះតែវាងមកដល់ហ្នឹងទៅ? |
| ពោ: | ចាំ! |
| សេងគា: | មកដល់ជំរុំហ្នឹង ជំរុំឈ្មោះអី? |
| ពោ: | ជំរុំសាយអេក ។ |
| សេងគា: | អញ្ចឹង១៩៨០ក៏នាំគ្នាមក? |
| ពោ: | ចាំ! |
| សេងគា: | អញ្ចឹងមកដោយសារការខុះខាតទេ? |
| ពោ: | ហ្នឹងអើយ ។ |
| សេងគា: | កាត់ពីថ្មគោលមកខាងណា? |
| ពោ: | ឡើងមកល្វាសឿ កាត់តាមផ្លូវហើយមកដល់ជំរុំ កាលហ្នឹងមកជាមួយខ្មែរក្រហមហើយចេះតែមកតាមគេមក ។ |
| សេងគា: | មកដល់កន្លែងហ្នឹងយ៉ាងម៉េចទៅ មានអង្ករមានអីហូបដែរ? |

ពៅៈ មកដល់ហ្នឹងខ្ញុំចូលទៅជួបបារាំង ។

សេងគាៈ អ៊ំបេះបារាំង?

ពៅៈ ចុះមានអី ខ្ញុំបកឲ្យគេ ហើយពេលដែលទៅជួបបារាំងគេឃើញយើងកូនច្រើន ។

សេងគាៈ កាលហ្នឹងអ៊ំរត់មកតែមួយគ្រួសារ ឬក៏រត់មកជាមួយគ្រួសារច្រើន?

ពៅៈ តាខ្ញុំអត់មកទេ ខ្ញុំមកតែជាមួយកូន ។

សេងគាៈ កូនប៉ុន្មាននាក់?

ពៅៈ កាលហ្នឹងកូនទើបតែបាន៣នាក់ ។

សេងគាៈ អញ្ចឹងមកពីនោះមិនមែន៨០ជាងទេ មិនស្រួល៨៥ហើយ?

ពៅៈ កាលហ្នឹងខ្ញុំមកដូចជា៨០ អ៎! ៩០ ។

សេងគាៈ អញ្ចឹង៩០គត់ហើយបានមក ។ ដល់ពេលវៀតណាមចូលធ្វើតែស្រែហើយនឹងចំការទេ?

ពៅៈ ចាំ!

សេងគាៈ ដល់ពេល៩០ក៏រត់មកនៅជំរុំ?

ពៅៈ ហ្នឹងអើយ ។

សេងគាៈ ហើយមកហ្នឹងនាំតែកូនមកទេ?

ពៅៈ ចាំ! នាំតែកូនមកហ្នឹង ។

សេងគាៈ មកជាមួយអ្នកណាគេកាលហ្នឹង?

ពៅៈ មកជាមួយមេខ្យល់គេ ។

សេងគាៈ មេខ្យល់ឈ្មោះអី?

ពៅៈ មេខ្យល់ឈ្មោះ រើន កាលហ្នឹងគេនាំមក ។

សេងគាៈ ហើយគេនាំមកហ្នឹងគេមានយកលុយទេ?

ពៅៈ គេយក៧០០លុយខ្មែរយើង ។

សេងគាៈ កាលហ្នឹង៧០០ច្រើនណាស់ ។ ហើយទាំងអស់គ្នាយក៧០០?

ពៅៈ ចាំ!

សេងគាៈ ដល់មកដល់អ៊ំចូលទៅជួប ដល់ហើយគេក៏ឲ្យនៅជំរុំទៅ?

ពៅៈ ចាំ!

សេងគាៈ ហើយពូអត់មកជាមួយទេ?

ពៅៈ		អត់មកផង គាត់មកក្រោយ ។

សេងគាៈ		ប៉ុន្មានឆ្នាំទៅបានជួបគ្នា ហើយមកដល់គេឲ្យនៅកន្លែងជំរុំហ្នឹង?

ពៅៈ		ចាំ!

សេងគាៈ		នៅជំរុំបានប៉ុន្មានឆ្នាំដែរ?

ពៅៈ		នៅដល់៩៣ ។

សេងគាៈ		អញ្ចឹងនៅបាន៣ឆ្នាំដែរ អញ្ចឹង៩៣បានត្រលប់ទៅវិញ?

ពៅៈ		ហ្នឹងអើយ ។

សេងគាៈ		ហើយម៉េចបានជាត្រលប់ទៅវិញ?

ពៅៈ		គេដឹកទៅ ។

សេងគាៈ		អ្នកណាអ្នកដឹកទៅ?

ពៅៈ		អង្គការគេហ្នឹង ។

សេងគាៈ		អង្គការខាងបារាំងហ្នឹងមែន?

ពៅៈ		ចាំ!

សេងគាៈ		ហើយអត់មានស្គាល់ឈ្មោះអង្គការអីទេ?

ពៅៈ		អត់ ។

សេងគាៈ		ដល់ពេលទៅដល់ស្រុកប៉ុន្មានខែបានទៅវិញ?

ពៅៈ		បានប៉ុន្មានខែទេ កាលហ្នឹងមកឆ្នាំផ្តាច់ខ្លួន ដូចជាឆ្នាំ៩៦ ។

សេងគាៈ		អញ្ចឹងដល់ពេល៩៦ត្រលប់មិនវិញទៀត?

ពៅៈ		ចាំ!

សេងគាៈ		មកវិញមកកន្លែងហ្នឹងហ្មង?

ពៅៈ		មកកន្លែងហ្នឹង ។

សេងគាៈ		ភូមិរំដួលហ្នឹង?

ពៅៈ		ចាំ!

សេងគាៈ		ដល់ពេលហើយមកជួបប្តីនៅហ្នឹងទៅ ហើយក៏ទៅចាប់ដីចាប់អីទៅ?

ពៅៈ		ហ្នឹងអើយ ។

សេងគាៈ		ហើយកាលមកដំបូងអ្នកណាគេមេគេ?

ពៅៈ		មេប្រចាំនៅនេះហ្នឹង?

សេងគា:		បាទ!

ពៅ:		មេឃុំសព្វថ្ងៃនេះ ឈ្មោះ ទុំ នេះ ។

សេងគា:		គាត់ម្ចាស់ស្រុកនៅហ្នឹង?

ពៅ:		ចាំ! ខ្មែរក្រហមចាស់នៅហ្នឹង ។

សេងគា:		ហើយកាលមកដល់ហ្នឹងគេឲ្យចាប់ដីនៅក្នុងចំការហ្នឹងម្នាក់ប៉ុន្មាន?

ពៅ:		កាលហ្នឹងគេមិនឲ្យយើងចាប់ទេ តែយើងមានកូនក្មួយយើងនាំចាប់ កាលហ្នឹងបាន១០-២០អ៊ែរអញ្ចឹងណាំ កាលហ្នឹងដីវានៅទូលាយ ។

សេងគា:		ហើយក៏ករកូនករចៅនៅហ្នឹងរហូតទៅ?

ពៅ:		ចាំ!

សេងគា:		ហើយខ្ញុំអស់អីសួរអ៊ំ ហើយចុងក្រោយខ្ញុំមានសំនួរមួយចង់សួរអ៊ំទាក់ទងនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់៤-៥នាក់ហ្នឹង ហើយតើគេកាត់ទោសអញ្ចឹងតើអ៊ំយល់យ៉ាងម៉េចដែរ កាត់ទោសមេដឹកនាំជាន់ខ្ពស់៣-៤នាក់អញ្ចឹង?

ពៅ:		កាត់ទោសដែលថាសម័យមុនមានសម្លាប់មនុស្សសម្លាប់អីហ្នឹង?

សេងគា:		បាទ! ហើយដឹកនាំមនុស្សសម្លាប់អញ្ចឹងណាំ?

ពៅ:		ខ្ញុំយល់ឃើញថា ការកាត់ទោសហ្នឹងវាសមហេតុសមផលដែរ ព្រោះយើងសម្លាប់គេប៉ុន្តែប្រជាជនយើងមើលទៅកាលសម័យហ្នឹង អ្នកដែលរត់មកតស៊ូហ្នឹងក៏កាត់ទោសត្រឹមត្រូវ កាត់ទោសចុះព្រោះយើងសម្លាប់មនុស្ស ។

សេងគា:		ហើយចុះបើតាមយោបល់អ៊ំផ្ទាល់ ដូចថាអ៊ំជាខ្មែរក្រហមមួយរូបដែរ តើអ៊ំគិតយ៉ាងណាដែរ?

ពៅ:		ខ្ញុំយល់ថាសព្វថ្ងៃយើងដើរទៅតាមច្បាប់ បើយើងយល់ថាកាលជំនាន់នោះមកពីមានមូលហេតុដែលយើងធ្វើសង្គ្រាមមកក៏វាមានមូលហេតុដែរ តែដល់ពេលយើងធ្វើជ្រុលពេកទៅច្បាប់ក៏គេត្រូវតែកាត់ទោសដែរ ។

សេងគា:		មូលហេតុយ៉ាងម៉េចទៅកាលពីមុនមក?

ពៅ:		យើងកាលសម័យមុនមកយើងធ្វើសង្គ្រាម តែសង្គ្រាមដូចថាសម្ដេចយើងមិនដឹកនាំឲ្យធ្វើសង្គ្រាម ដល់ពេលធ្វើអ្នកធ្វើក្រោយហ្នឹងគឺធ្វើជ្រុលណាំ ។

សេងគា:		អញ្ចឹងអ៊ំគិតថាការកាត់ទោសហ្នឹងសមហេតុសមផលដែរ ដូចថាអ្នកហ្នឹងធ្វើជ្រុល?

ពោះ អានេះដូចថាបើយើងវិភាគឲ្យដល់ទៅ បើយើងជាប្រជាជនយើងចង់ឲ្យកាត់ហើយ បើច្បាប់ត្រូវកាត់ហើយ ប្រជាជនមិនដឹងថាម៉េច ។

សេងគា: បើតាមចិត្តរបស់អ៊ំ អ៊ំមិនចង់ឲ្យកាត់ដោយសារមូលហេតុអី?

ពោះ ដូចថាខ្មែរក្រហមកាលពីសម័យមុនវាមានអ្នកដឹកនាំឲ្យធ្វើណា៎ ហើយធ្វើវាចេះតែជ្រុលណា៎ ដល់ពេលក្រោយមកវាចេះតែមានបញ្ហា ។

សេងគា: តែបើតាមចិត្តរបស់អ៊ំៗមិនចង់ឲ្យកាត់ ទេ តែដោយសារតែច្បាប់គេតម្រូវឲ្យកាត់?

ពោះ ហើយដោយសារវាស្របនឹងច្បាប់ ។

សេងគា: ហើយចុងក្រោយអ៊ំមានពាក្យពេជន៍ចង់និយាយបន្ថែមទៀតទេ នូវអ្វីដែលខ្ញុំមិនទាន់បានសួរ អ៊ំមានអីចង់ប្រាប់ទៀតទេ?

ពោះ អត់មានអីទេ ។

សេងគា: អញ្ចឹងខ្ញុំសូមអរគុណអ៊ំដែលបានផ្តល់ពេលវេលាសំណេះសំណាលជាមួយខ្ញុំ ហើយម៉េញហ្នឹងក៏មិនទាន់បានសុំអ៊ំដែរ ខ្ញុំអ័តជាសម្លេងអញ្ចឹង ហើយយកសម្លេងរបស់អ៊ំទៅចងក្រងជាទស្សនាវដ្តីស្វែងរកការពិត ហើយសាច់រឿងនេះនិយាយពីសាច់រឿងរបស់អ៊ំផ្ទាល់ដើម្បីយកទៅចងក្រងជាឯកសារ តើអ៊ំអត់មានថាអីទេ?

ពោះ អត់មានថាអីទេ ។

សេងគា: ហើយឪពុកម្តាយខ្ញុំក៏គេចុះក្នុងទស្សនាវដ្តីដែរ ។

ពោះ គាត់នេះខាងណាដែរ?

សេងគា: គាត់អ្នកបាត់ដំបង នៅវត្តឯកភ្នំ ។

ពោះ គាត់នៅរស់ទេ?

សេងគា: គាត់នៅរស់ទាំង២នាក់ ហើយគាត់ធ្លាប់មកថ្មគោលដែរហ្នឹង ។

ពោះ ចា៎!

សេងគា: អញ្ចឹងអរគុណអ៊ំច្រើន ។